**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**នាយកដ្ឋានព័ត៌មាន**

# សេចក្តីជូនព័ត៌មាន
# ស្តីពីលទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៣២
# ថ្ងៃទី ២៧-២៨ ខែមេសា ឆ្នាំ២០១៨ ប្រទេសសិង្ហបុរី

------------------

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៣២ ក្រោមមូលបទ "**ភាពរឹងមាំ និងនវានុវត្តន៍របស់អាស៊ាន**" ដែលបានប្រព្រឹត្តទៅពីថ្ងៃទី ២៧ ដល់ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៨ នៅប្រទេសសិង្ហបុរី តបតាមការអញ្ជើញរបស់ ឯកឧត្តម លី សៀន ឡុង នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសិង្ហបុរី និងជាប្រធានកិច្ចប្រជុំកំពូល។

នៅក្នុងកិច្ចប្រជុំកំពូល ថ្នាក់ដឹកនាំបានធ្វើការអះអាងឡើងវិញអំពីសារសំខាន់ក្នុងការរក្សាតួនាទីស្នូល និងឯកភាពរបស់អាស៊ាន ក្នុងកិច្ចខិតខំប្រឹងប្រែងកសាងសហគមន៍ និងការជាប់ពាក់ព័ន្ធជាមួយដៃគូខាងក្រៅ ព្រមទាំងស្វាគមន៍នូវគំនិតផ្តួចផ្តើមនានា ក្នុងការពង្រឹងនិម្មាបនកម្មតំបន់ ដែលបើកចំហ មានតម្លាភាព បរិយាប័ន្ន និងឈរលើយន្តការនានាដែលដឹកនាំដោយអាស៊ាន។ ថ្នាក់ដឹកនាំបានប្តេជ្ញាចិត្តក្នុងការរក្សា និងលើកកម្ពស់សន្តិភាព សន្តិសុខ និងស្ថិរភាពតំបន់ ការដោះស្រាយជម្លោះដោយសន្តិវិធី មិនជ្រើសរើសការគំរាមកំហែង ឬការប្រើកម្លាំង ដោយអនុលោមទៅតាមគោលការណ៍ច្បាប់អន្តរជាតិដែលមានការទទួលស្គាល់ជាសកល រួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រឆ្នាំ១៩៨២។

ចំពោះការកសាងសហគមន៍អាស៊ាន ថ្នាក់ដឹកនាំបានធ្វើការពិភាក្សាប្រកបដោយលទ្ធផល និងបានតាំងចិត្តពង្រឹងកិច្ចសហប្រតិបត្តិការជិតស្និទ្ធ ក្នុងការកសាងភាពរឹងមាំ និងនវានុវត្តន៍របស់អាស៊ាន ការបង្កើតបណ្តាញទីក្រុងឆ្លាតអាស៊ាន កិច្ចសហប្រតិបត្តិការសន្តិសុខតាមអ៊ិនធឺណេត និងសន្ធិសញ្ញាបត្យាប័នអាស៊ាន។ ថ្នាក់ដឹកនាំបានយល់ព្រមជំរុញថែមទៀតដល់នវានុវត្តន៍ និងពាណិជ្ជកម្មអេឡិចត្រូនិក ពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងកាត់ព្រំដែន សមាហរណកម្មវិនិយោគ និងគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ក្របខណ្ឌការងារសមាហរណកម្មឌីជីថលអាស៊ាន។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ថ្នាក់ដឹកនាំក៏បានធ្វើការពិភាក្សាយ៉ាងស៊ីជម្រៅ និងផ្លាស់ប្តូរទស្សនៈលើការវិវឌ្ឍនាពេលថ្មីៗនេះ លើបញ្ហាដែលជាការព្រួយបារម្ភរួម ក្នុងនោះ ថ្នាក់ដឹកនាំមានសេចក្តីរីករាយចំពោះការវិវឌ្ឍទៅមុខ ការរៀបចំសេចក្តីព្រាងក្រមប្រតិបត្តិ ដែលផ្តល់ភាពអនុគ្រោះដល់ការកសាងទំនុកចិត្ត និងការជឿជាក់ សម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងឡាយ ហើយបានរំពឹងទុកដល់ការបញ្ចប់អោយបានឆាប់រហ័សនូវក្រមប្រតិបត្តិនេះ។ ចំពោះបញ្ហាឧបទ្វីបកូរ៉េ ថ្នាក់ដឹកនាំមានការលើកទឹកចិត្តចំពោះកិច្ចប្រជុំកំពូលអន្តរកូរ៉េ រវាងឯកឧត្តម ម៉ូន ជេ អ៊ីន និងឯកឧត្តម គីម ជុង អ៊ុន និងបានបង្ហាញក្តីសង្ឃឹមថា កិច្ចប្រជុំកំពូលដ៏មានសារៈសំខាន់នេះ នឹងនាំឆ្ពោះទៅរកការបន្ធូរបន្ថយភាពតានតឹងនៅឧបទ្វីបកូរ៉េ និងបើកគ្រឹះដ៏សមប្រកបមួយក្នុងការរួមចំណែកដល់សន្តិភាព និងសន្តិសុខ នៅក្នុងនិងក្រៅតំបន់។ ចំពោះបញ្ហានៅរដ្ឋរ៉ាខាញនៃប្រទេសមីយ៉ាន់ម៉ា ថ្នាក់ដឹកនាំមានការព្រួយបារម្ភដល់ទិដ្ឋភាពមនុស្សធម៌។ ថ្នាក់ដឹកនាំបានត្រៀមជាស្រេចក្នុងការប្រមូលកិច្ចគាំទ្រតាមរយៈមជ្ឈមណ្ឌលសម្របសម្រួលជំនួយមនុស្សធម៌របស់អាស៊ានស្តីពីគ្រោះមហន្តរាយ ព្រមទាំងលើកទឹកចិត្តដល់មីយ៉ាន់ម៉ា និងបង់ក្លាដេស ធ្វើការដោះស្រាយរួមគ្នា ការវិលត្រលប់មកវិញដោយស្ម័គ្រចិត្ត ចំពោះជនដែលទទួលការប៉ះពាល់នានា។

កិច្ចប្រជុំកំពូលអាស៊ានលើកទី៣២ បានចេញផ្សាយសេចក្តីប្រកាសរបស់ប្រធានកិច្ចប្រជុំកំពូល (គោរពជូនភ្ជាប់) ព្រមទាំងបានអនុម័ត ១) ទស្សនវិស័យថ្នាក់ដឹកនាំអាស៊ានស្តីពីភាពរឹងមាំនិងនវានុវត្តន៍របស់អាស៊ាន ២) ឯកសារទស្សនទានស្តីពីបណ្តាញទីក្រុងឆ្លាតអាស៊ាន និង ៣) សេចក្តីប្រកាសរបស់ថ្នាក់ដឹកនាំអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត។ កិច្ចប្រជុំកំពូលក៏បានកត់សំគាល់លើឯកសារមួយចំនួនដូចជា របាយការណ៍របស់អគ្គលេខាធិការអាស៊ានស្តីពីការងារប្រចាំឆ្នាំរបស់អាស៊ាន វឌ្ឍនភាពនៃការអនុវត្តផែនការលម្អិតសហគមន៍នយោបាយ-សន្តិសុខអាស៊ាន ផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ាន និងផែនការលម្អិតសហគមន៍សង្គម-វប្បធម៌អាស៊ាន។

នៅក្នុងកិច្ចប្រជុំកំពូលពេញអង្គ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានធ្វើការគូសបញ្ជាក់នូវចំណុចសំខាន់ៗមួយចុះចំនួនក្នុងការពង្រឹងសហគមន៍អាស៊ាន។ សម្រង់សុន្ទរកថារបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** មានគោរពជូនភ្ជាប់។

ថ្ងៃ ចន្ទ ១រោច ខែពិសាខ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៨